**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ.០០៥.....សហវ.........

# សេចក្ដីណែនាំ

## ស្ដីពី

## ការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញ នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន និង ក្រសួងកិច្ចការនារី

ស្របតាមផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា និង ផែនការពង្រីកការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី ៣ (២០២១-២០២៥) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអភិវឌ្ឍ និង រៀបចំមុខងារលទ្ធកម្មពេញលេញរួចរាល់ស្របតាមផែនការដែលបានគ្រោងទុក ។ មុខងារលទ្ធកម្មពេញលេញនេះ ចែកចេញជា ៤ ផ្នែក គឺ ទី១-ផ្នែកគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ, ទី២-ផ្នែកផែនការលទ្ធកម្ម, ទី៣-ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃ និង ទី៤-ផ្នែកគ្រប់គ្រងកិច្ចសន្យា ដែលនឹងជួយសម្រួលដល់ការគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ, ការគ្រប់គ្រងនិងអនុវត្តផែនការលទ្ធកម្ម, ការគ្រប់គ្រងដំណើរការដេញថ្លៃ និង ការគ្រប់គ្រងកិច្ចសន្យា ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ។ នៅជំហានដំបូងនេះ មុខងារលទ្ធកម្មពេញលេញ នឹងដាក់ឱ្យអនុវត្តសាកល្បងនៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពលទ្ធកម្មនៃក្រសួងចំនួន ៣ គឺ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងព័ត៌មាន និង ក្រសួងកិច្ចការនារី មុននឹងបន្តដាក់ឱ្យអនុវត្តចំពោះក្រសួង-ស្ថាប័នផ្សេងទៀតនៅជំហានបន្ទាប់ ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានរតនាគារជាតិ និង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ នឹងត្រូវចូលរួមអនុវត្តសាកល្បងផ្នែកផែនការលទ្ធកម្ម នៃមុខងារលទ្ធកម្មពេញលេញផងដែរនៅជំហានដំបូងនេះ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការអនុវត្តមុខងារលទ្ធកម្មពេញលេញ នៃប្រព័ន្ធ FMIS ដូចតទៅ÷

### ១. ការអនុវត្តក្នុងផ្នែក “គ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ”

១.១. ផ្នែកគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ផ្នែកនេះ នៅក្នុងប្រព័ន្ធមានប្រតិបត្តិការដែលត្រូវបង្កើត ពិនិត្យនិងផ្ទៀងផ្ទាត់ និង អនុម័ត ចំនួន ២ គឺ ប្រតិបត្តិការបង្កើតអ្នកដេញថ្លៃថ្មី និង ប្រតិបត្តិការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកដេញថ្លៃដែលបានចុះបញ្ជីរួច ។

១.២. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើត ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកដេញថ្លៃ* ត្រូវធ្វើការបង្កើត ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកដេញថ្លៃនៅក្នុងប្រព័ន្ធ នៅពេលមានការស្នើសុំចុះឈ្មោះអ្នកដេញថ្លៃថ្មី ឬ នៅពេលមានការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានពីអ្នកដេញថ្លៃដែលបានចុះបញ្ជីរួច ដោយធ្វើការបញ្ចូលរាល់ព័ត៌មានអ្នកដេញថ្លៃនៅក្នុងប្រព័ន្ធ ទៅកាន់អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិពិនិត្យនិងផ្ទៀងផ្ទាត់ និង បន្ទាប់ពីការពិនិត្យនិងផ្ទៀងផ្ទាត់ ឃើញថាត្រឹមត្រូវ នឹងបញ្ជូនបន្តទៅកាន់អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត ។ បន្ទាប់ពីទទួលបានការអនុម័តរួចនៅក្នុងប្រព័ន្ធ, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើត* ត្រូវធ្វើការបោះពុម្ពវិញ្ញាបនបត្រអ្នកដេញថ្លៃចេញពីប្រព័ន្ធ ។

១.៣. បន្ទាប់ពីទទួលបានការឯកភាពជាផ្លូវការពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការស្នើសុំចុះឈ្មោះថ្មី ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានពីអ្នកដេញថ្លៃ, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិពិនិត្យនិងផ្ទៀងផ្ទាត់* និង *អ្នកប្រើប្រាស់ប្រព័ន្ធដែល*

*ទទួលសិទ្ធិអនុម័ត* ត្រូវធ្វើការពិនិត្យឱ្យបានហ្មត់ចត់ មុនធ្វើការអនុម័តលើព័ត៌មានរបស់អ្នកដេញថ្លៃដែលបានបង្កើត ឬ ធ្វើបច្ចុប្បន្នភាពរួចក្នុងចំណុច ១.២ ខាងលើ តាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ ។

**២. ការអនុវត្តក្នុងផ្នែក "ផែនការលទ្ធកម្ម"**

**២.១.** ផ្នែកផែនការលទ្ធកម្ម អនុវត្តនៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ២ គឺអគ្គនាយកដ្ឋានរតនាគារជាតិ និង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, នៅអង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗដូចមានរៀបរាប់ខាងលើ និង នៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ផ្នែកនេះ នៅក្នុងប្រព័ន្ធមានប្រតិបត្តិការដែលត្រូវបង្កើត ពិនិត្យនិងផ្ទៀងផ្ទាត់ និង អនុម័ត ចំនួន ២ គឺ ប្រតិបត្តិការបង្កើតផែនការលទ្ធកម្មប្រចាំឆ្នាំ និង ប្រតិបត្តិការកែតម្រូវផែនការលទ្ធកម្ម ។

២.២. ចំពោះផែនការលទ្ធកម្មរបស់អគ្គនាយកដ្ឋានរតនាគារជាតិ និង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា បន្ទាប់ពីបានរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរួចរាល់, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការ របស់អង្គភាពថវិកានីមួយៗ* ត្រូវបង្កើតប្រតិបត្តិការផែនការលទ្ធកម្មប្រចាំឆ្នាំ និង ធ្វើការពិនិត្យអនុម័តតាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ រួចបញ្ជូនប្រតិបត្តិការបន្ត ។

២.៣. ចំពោះផែនការលទ្ធកម្មរបស់អគ្គនាយកដ្ឋានរតនាគារជាតិ និង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា បន្ទាប់ពីទទួលបានឯកសារ និង ប្រតិបត្តិការនៅក្នុងប្រព័ន្ធអំពីផែនការលទ្ធកម្មប្រចាំឆ្នាំរបស់អង្គភាពថវិកាទាំង ២, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការ របស់អង្គភាពលទ្ធកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវបន្តធ្វើការពិនិត្យប្រតិបត្តិការដោយធ្វើការផ្ទៀតផ្ទាត់ជាមួយឧបសម្ព័ន្ធនៃផែនការលទ្ធកម្មនោះឱ្យបានហ្មត់ចត់ រួចធ្វើការអនុម័តតាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ រួចបញ្ជូនប្រតិបត្តិការបន្ត ។

២.៤. ករណីជាផែនការលទ្ធកម្មប្រចាំឆ្នាំ និង ឧបសម្ព័ន្ធផែនការលទ្ធកម្មផ្សេងទៀតក្នុងក្របខណ្ឌក្រសួងនីមួយៗដូចមានរៀបរាប់ខាងលើ បន្ទាប់ពីទទួលបាននូវឯកសារផែនការលទ្ធកម្មប្រចាំឆ្នាំគ្រប់គ្រាន់, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការរបស់អង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗ* ត្រូវបង្កើតប្រតិបត្តិការផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់ក្រសួងនីមួយៗ (រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំងថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន) ផ្អែកលើឧបសម្ព័ន្ធផែនការលទ្ធកម្ម រួចធ្វើការពិនិត្យលើប្រតិបត្តិការផែនការលទ្ធកម្មនោះឱ្យបានហ្មត់ចត់ មុនធ្វើការអនុម័ត តាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ រួចបញ្ជូនប្រតិបត្តិការបន្ត ។

២.៥. បន្ទាប់ពីទទួលបាននូវឯកសារផ្លូវការ និង ប្រតិបត្តិការនៅក្នុងប្រព័ន្ធសម្រាប់ផែនការលទ្ធកម្មប្រចាំឆ្នាំ និង ឧបសម្ព័ន្ធរបស់ក្រសួងនីមួយៗ រួមទាំង អគ្គនាយកដ្ឋានរតនាគារជាតិ និង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត របស់អគ្គនាយក-ដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់ លើប្រតិបត្តិការផែនការលទ្ធកម្មនោះឱ្យបានហ្មត់ចត់ មុននឹងអនុម័តបញ្ចប់ចុងក្រោយ តាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនអនុញ្ញាតឱ្យផ្ដល់ធានាចំណាយឡើយ ចំពោះគម្រោងចំណាយណាដែលមិនបានកត់ត្រានៅក្នុងផែនការលទ្ធកម្ម។

***២.៦. សម្រាប់ករណីកែតម្រូវផែនការលទ្ធកម្ម អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិកែតម្រូវ, អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត លើប្រតិបត្តិការកែតម្រូវផែនការលទ្ធកម្មនៅក្នុងប្រព័ន្ធនៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, អង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗ និង នៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តដូចគ្នានឹងការអនុវត្តការបង្កើតផែនការលទ្ធកម្មក្នុងចំណុច ២.២., ២.៣, ២.៤ និង ២.៥ ខាងលើ ។***

**៣. ការអនុវត្តក្នុងផ្នែក "គ្រប់គ្រងដំណើរការដេញថ្លៃ"**

៣.១. ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃ អនុវត្តនៅអង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗ និង អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែប៉ុណ្ណោះ ។ ផ្នែកនេះ មានប្រតិបត្តិការចំនួន ៤ រួមមាន ប្រតិបត្តិការកម្មវិធីដេញថ្លៃ, ប្រតិបត្តិការការចូលរួមដេញថ្លៃ, ប្រតិបត្តិការការវាយតម្លៃការដេញថ្លៃ និង ប្រតិបត្តិការការប្រកាសជ័យលាភីដេញថ្លៃ ។

៣.២. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការក្នុងផ្នែកដំណើរការដេញថ្លៃ របស់អង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗ* ត្រូវបង្កើតប្រតិបត្តិការកម្មវិធីដេញថ្លៃ, ប្រតិបត្តិការការចូលរួមដេញថ្លៃ, ប្រតិបត្តិការការវាយតម្លៃការដេញថ្លៃ និង ប្រតិបត្តិការការប្រកាសជ័យលាភីដេញថ្លៃ នៅក្នុងប្រព័ន្ធ បន្ទាប់ពីបញ្ចប់ដំណាក់កាលនីមួយៗនៃដំណើរការដេញថ្លៃ ។ សម្រាប់ប្រតិបត្តិការកម្មវិធីដេញថ្លៃ និង ប្រតិបត្តិការការវាយតម្លៃការដេញថ្លៃ អ្នកប្រើប្រាស់ប្រព័ន្ធត្រូវធ្វើការបញ្ជូនប្រតិបត្តិការបន្ត ។

៣.៣. បន្ទាប់ពីទទួលបាននូវឯកសារផ្លូវការ និង ប្រតិបត្តិការកម្មវិធីដេញថ្លៃ ឬ ប្រតិបត្តិការការវាយតម្លៃការដេញថ្លៃនៅក្នុងប្រព័ន្ធ, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត របស់អង្គភាពលទ្ធកម្មនៃក្រសួងសាមី* ត្រូវបន្តធ្វើការពិនិត្យផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ និង អនុម័តបញ្ចប់ប្រតិបត្តិការនៅក្នុងប្រព័ន្ធ សម្រាប់ករណីការដេញថ្លៃក្រោមសិទ្ធិសម្រេច ។ ដោយឡែក ករណីការដេញថ្លៃលើសសិទ្ធិសម្រេច អ្នកប្រើប្រាស់ប្រព័ន្ធត្រូវបញ្ជូនប្រតិបត្តិការបន្ត បន្ទាប់ពីបានអនុម័តរួច ។

៣.៤. សម្រាប់ករណីការដេញថ្លៃលើសសិទ្ធិសម្រេច, បន្ទាប់ពីទទួលបានឯកសារផ្លូវការ និង ប្រតិបត្តិការកម្មវិធីដេញថ្លៃ ឬ ប្រតិបត្តិការការវាយតម្លៃការដេញថ្លៃនៅក្នុងប្រព័ន្ធ, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័ត របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវបន្តធ្វើការពិនិត្យផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ និង ធ្វើការអនុម័តបញ្ចប់នៅក្នុងប្រព័ន្ធ ។

**៤. ការអនុវត្តក្នុងផ្នែក "ការគ្រប់គ្រងកិច្ចសន្យា"**

៤.១. ផ្នែកគ្រប់គ្រងកិច្ចសន្យា អនុវត្តនៅអង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗ និង អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែប៉ុណ្ណោះ ។ ផ្នែកនេះ មានប្រតិបត្តិការចំនួន ៣ គឺ កិច្ចសន្យាលទ្ធកម្មសាធារណៈ, ការបញ្ជាទិញ និង របាយការណ៍វាយតម្លៃវឌ្ឍនភាពការងារឬវិញ្ញាបនបត្របញ្ចប់ការងារ ។

៤.២. បន្ទាប់ពីប្រកាសអ្នកដេញថ្លៃឈ្នះ និង ចុះកិច្ចសន្យារួចរាល់ដោយក្រសួងសាមីជាមួយនឹងអ្នកដេញថ្លៃឈ្នះ, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តប្រតិបត្តិការរបស់អង្គភាពលទ្ធកម្មនៃក្រសួងសាមី* ត្រូវបង្កើតប្រតិបត្តិការកិច្ចសន្យាលទ្ធកម្មសាធារណៈ និង ធ្វើការពិនិត្យឱ្យបានហ្មត់ចត់មុនធ្វើការអនុម័តប្រតិបត្តិការកិច្ចសន្យាលទ្ធកម្មសាធារណៈនោះ តាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ សម្រាប់ករណីកិច្ចសន្យាក្រោមសិទ្ធិសម្រេច។ ដោយឡែក ករណីការដេញថ្លៃលើសសិទ្ធិសម្រេច អ្នកប្រើប្រាស់ប្រព័ន្ធត្រូវបញ្ជូនប្រតិបត្តិការបន្ត ។

៤.៣. ករណីកិច្ចសន្យាលើសសិទ្ធិសម្រេច, បន្ទាប់ពីទទួលបានឯកសារកិច្ចសន្យាជាផ្លូវការ និង ប្រតិបត្តិការនៅក្នុងប្រព័ន្ធ, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ និង អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ត្រូវបន្តត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ និង ធ្វើការអនុម័តលើប្រតិបត្តិការកិច្ចសន្យាលទ្ធកម្មសាធារណៈ តាមតួនាទីរៀងខ្លួននៅក្នុងប្រព័ន្ធ ដើម្បីបញ្ចប់ប្រតិបត្តិការកិច្ចសន្យា លើសសិទ្ធិសម្រេច ។

៤.៤. បន្ទាប់ពីទទួលបានលិខិតប្រគល់ទទួល និង ឯកសារពាក់ព័ន្ធផ្សេងៗ, *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើតប្រតិបត្តិការបញ្ជាទិញរបស់អង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗ* ត្រូវបង្កើតប្រតិបត្តិការបញ្ជាទិញ និង ប្រតិបត្តិការប្រគល់ទទួលនៅក្នុងប្រព័ន្ធ ។ *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបោះពុម្ព របស់អង្គភាពលទ្ធកម្មនៃក្រសួងនីមួយៗ និង អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* អាចធ្វើការបោះពុម្ពរបាយការណ៍វាយតម្លៃវឌ្ឍនភាពការងារចេញពី

ប្រព័ន្ធដើម្បីធ្វើការត្រួតពិនិត្យនិងតាមដានការអនុវត្តកិច្ចសន្យា ឬ បោះពុម្ពវិញ្ញាបនបត្របញ្ចប់ការងារបន្ទាប់ពីបង្កើតប្រតិបត្តិការប្រគល់ទទួលរួច ។

ក្រសួង-ស្ថាប័ន អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធនានាត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែបឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ក្រសួងកិច្ចការនារី
- ក្រសួងព័ត៌មាន
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា
- អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ.....០០៩.......... ចុះថ្ងៃទី.....៨...កក្កដា...២០២១.....

ស្តីពី ការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញ នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ (FMIS) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន និង ក្រសួងកិច្ចការនារី

## លំហូរនៃការប្រើប្រាស់មុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធ FMIS

### ១. លំហូរក្នុងផ្នែកគ្រប់គ្រងបញ្ជីឈ្មោះអ្នកដេញថ្លៃ




### ២. លំហូរក្នុងផ្នែកផែនការលទ្ធកម្ម

#### ២.១. ករណីផែនការលទ្ធកម្មដែលបង្កើតក្នុងប្រព័ន្ធដោយអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ



### ២. ២. ករណីជាផែនការលទ្ធកម្មក្នុងក្របខណ្ឌក្រសួងនីមួយៗ (លើកលែងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញដែលបង្កើតដោយខ្លួនឯង)




## ៣. ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃ

### ៣.១. ប្រតិបត្តិការកម្មវិធីដេញថ្លៃក្រោមសិទ្ធិសម្រេច



### ៣.២.ប្រតិបត្តិការវាយតម្លៃការដេញថ្លៃក្រោមសិទ្ធិសម្រេច




### ៣.៣.ប្រតិបត្តិការកម្មវិធីដេញថ្លៃលើសសិទ្ធិសម្រេច



### ៣.៤. ប្រតិបត្តិការវាយតម្លៃការដេញថ្លៃលើសសិទ្ធិសម្រេច




## ៤. ផ្នែកគ្រប់គ្រងកិច្ចសន្យា

### ៤.១. ប្រតិបត្តិការកិច្ចសន្យាក្រោមសិទ្ធិសម្រេច



## ៤.២. ប្រតិបត្តិការកិច្ចសន្យាដេញថ្លៃលើសសិទ្ធិសម្រេច

